ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
------
សភាផ្នែក ព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៣៥
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥៨

សាលដីកា
------
លេខ : ០១
ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៥៩

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣ ខែកុម្ភៈ - ឆ្នាំ១៩៥៩ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ទិត មន្ត្រី ប្រធាន
២ - លោក ឈឹម ស៊ីផល ចៅក្រម
៣ - លោក ព្រាក់ គឹមសាន ចៅក្រមរាយការណ៍
៤ - លោក សោម សិរីវឌ្ឍ ចៅក្រម
៥ - លោក យស់ ស្វេខឿន ចៅក្រម

ក្រឡាបញ្ជី លោក ប៊ុល វណ្ណា

តំណាងមហាអយ្យការ
លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១១៤១ ចុះថ្ងៃទី២៤ ខែមិថុនា - ឆ្នាំ១៩៥៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៣៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥៨ របស់តុលាការកំពូល ។

ពីបទ : ប៉ុនប៉ងធ្វើអោយខូចខាតដោយចេតនាដល់ទ្រព្យសម្បត្តិអ្នកដទៃ និងមិនគោរព ភារកិច្ចរបស់ខ្លួន ។ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែវិច្ឆិកា ឆ្នាំ១៩៥៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៨២ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ទេង គឹមអ៊ី ភេទប្រុសអាយុ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ១៧៥ ផ្លូវប៉ាស្ទ័រ សង្កាត់ចតុមុខ ខណ្ឌដូនពេញ - ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ហួត ទេង "ស" ម្តាយឈ្មោះ ហួត យីទេង "ស" ប្រពន្ធឈ្មោះ - ម៉ារី ល្វីស មានកូនបីនាក់ ត្រូវឃុំខ្លួននៅថ្ងៃទី២២ - ៥ - ៥៧ ។

- ជនជាប់ចោទឈ្មោះ ទេង និស្ស័យ ភេទប្រុសអាយុ៣២ឆ្នាំ ជាតិបារាំង កើតនៅស្រុកអូរីយ ក្រុងអឺរ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ១៧៥ ផ្លូវប៉ាស្ទ័រ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ទេង គឹមអ៊ី "រ" ម្តាយឈ្មោះ ម៉ារី ល្វីស "រ" នៅលីវ ត្រូវឃុំខ្លួននៅថ្ងៃទី២២ - ៥ - ៥៧ ។

មេធាវី ការពារអោយជនជាប់ចោទឈ្មោះទេង គឹមអ៊ី លោកស្រី វ៉ែកវ គឹមសាន

- ដើមបណ្តឹងរដ្ឋប្បវេណី ធនាគារជាតិនៃកម្ពុជា តំណាងដោយលោក កាំង គុងហាង

ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ កើតនៅឃុំបុស្សស្លាវ ស្រុកក្រចេះ ខេត្តក្រចេះ ទីលំនៅ បច្ចុប្បន្ន ផ្ទះលេខ១៣អឺ០ ផ្លូវព្រះកុសុមៈ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ឪពុកឈ្មោះ កាង កាត់ "ឈ" ម្តាយឈ្មោះ គ្រុយ គឹមហួយ "ទ" ប្រពន្ធឈ្មោះនាង សោ គៀន មានកូន ៣នាក់ ។

- មេធាវី គ្មាន

- តាមទេយ្យការណ៍ចុះថ្ងៃទី២៤ - ០១ - ៨៧ ធនាគារជាតិ នៃកម្ពុជា បានប្តឹងសុំអោយ ចោទប្រកាន់ និង ផ្តន្ទាទោសឈ្មោះ ទេង គឹមអ៊ី និង ទេង និស្ស័យ តាមមាត្រា៥២ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល និង មាត្រា១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ និង សុំអោយធនាគារ ខ្មែរ បង់ប្រាក់ជាកពិន័យ ចំនួន ៣០.០០០.០០០រៀល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញ ថា : សូមតម្កល់ការចោទប្រកាន់លើឈ្មោះ ទេង និស្ស័យ និង ឈ្មោះទេង គឹមអ៊ី ពីបទ ប៉ុនប៉ងធ្វើអោយ ខូចខាតដោយចេតនា នូវទ្រព្យសម្បត្តិអ្នកដទៃ និង មិនគោរពភារកិច្ចរបស់ខ្លួន ។

បានឃើញសាលក្រមលេខ១០៧ "ក" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៨៧ របស់តុលាការ ក្រុងភ្នំពេញ ដែលបានសំរេច :

១ - ផ្តន្ទាទោសលើ :

ក - ឈ្មោះ ទេង គឹមអ៊ី ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០១ឆ្នាំ គិតពីថ្ងៃឃុំខ្លួន "២២ - ៥ - ៨៧" ពីបទ ប៉ុនប៉ងធ្វើអោយខូចខាតដោយចេតនានូវ ទ្រព្យសម្បត្តិអ្នកដទៃ និង មិនគោរពភារកិច្ចរបស់ខ្លួន តាមមាត្រា៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ ។

ខ - ឈ្មោះ ទេង និស្ស័យ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិច្វាំង ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ គិតពីថ្ងៃឃុំខ្លួន "២២ - ៥ - ៨៧" តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារ កំណត់ ០៣ខែ សល់ពីនោះត្រូវព្យួរទុកទាំងអស់ ដោយទុករយៈពេលសាកល្បង ៥ឆ្នាំ តាមមាត្រា៥២ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា១៧ នៃច្បាប់ ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ ។ បទល្មើសប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែវិច្ឆិកា ឆ្នាំ១៩៨៦ ។

២ - ផ្តន្ទាទោសពិន័យ ឈ្មោះទេង គឹមអ៊ី និង ទេង និស្ស័យ ជាប្រាក់ចំនួន - ៣០.០០០.០០០រៀល អោយទៅធនាគារជាតិ នៃកម្ពុជា តាមមាត្រា១៧ នៃច្បាប់ស្តីពីការ គ្រប់គ្រងស្ថាប័នរូបិយវត្ថុ ។ សំណូមពរលើសពីនេះត្រូវបដិសេធចោល ។

៣ - រឹបអូសលិខិតធានាចុះហត្ថលេខាដោយឈ្មោះ ទេង គឹមអ៊ី និង ទេង និស្ស័យ លេខ : - ចេកាអិលទេហ្វ ០១ ចុះថ្ងៃទី០៦ - ១១ - ៨៦ ដែលមានទឹកប្រាក់ចំនួន៣០០.០០០.០០០- ដុល្លាអាមេរិក ។

- ចេកាអិលទេហ្វ ០២ ចុះថ្ងៃទី០៨ - ១១ - ៨៦ ដែលមានទឹកប្រាក់ចំនួន២០០.០០០.០០០- ដុល្លាអាមេរិក ។

- ចេកាអិលទេហ្វ ០៧ ចុះថ្ងៃទី១៤ - ១១ - ៨៦ ដែលមានទឹកប្រាក់ចំនួន១៩២.០០០.០០០- ដុល្លាអាមេរិក ដែលមានបត្តគាហក ក្រុមហ៊ុនខ្មែរដំណាំកៅស៊ូ ។

- ចេកាអិលទេហ្វ ០៣ ចុះថ្ងៃទី០៨ - ១១ - ៨៦ ដែលមានទឹកប្រាក់ចំនួន ៥០.០០០.០០០- ដុល្លាអាមេរិក ។

- ចេកាអិលទេហ្វ ០៥ ចុះថ្ងៃទី០៨ - ១១ - ៨៦ ដែលមានទឹកប្រាក់ចំនួន៣០០.០០០.០០០- ដុល្លាអាមេរិក ដែលមានបត្តគាហកក្រុមហ៊ុនខ្មែរអភិវឌ្ឍសង្គម ។

- ចេកាអិលទេហ្វ ០៦ ចុះថ្ងៃទី១២ - ១១ - ៨៦ ដែលមានទឹកប្រាក់ចំនួន ៥០.០០០.០០០- ដុល្លាអាមេរិក ដែលមានបត្តគាហក សមាគមអភិវឌ្ឍកសិឧស្សាហកម្ម តាខ្មៅ ។

និង វិញ្ញាបនកម្ម ក្នុងប្រតិបត្តិការលេខ ០៤តេភិនតេ តេលេក្រាម ចុះថ្ងៃទី០៣ - ០១ - ៨៧

ដើម្បីប្រតិរោធ ចោលជាអសារបង់ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤ - សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះសំរេចបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦៧ "ក" ចុះថ្ងៃទី ០៧-១០-៨៧ របស់ឈ្មោះ - កាង គួងហ៊ាង តំណាងធនាគារជាតិនៃកម្ពុជា និង ឈ្មោះហេង គឹមអ៊ី - ហេង និស្ស័យ តាមបណ្តឹងលេខ ៨០ក ចុះថ្ងៃទី២៧-៨-៨៧ ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌ លេខ ១០៧ ក ចុះថ្ងៃទី-១១-៨-១៩៨៧ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា : សូមតម្កល់សាលក្រមរបស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ បានសំរេច :

១ - ទទួលពាក្យសុំដកបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ហេង គឹមអ៊ី និង ហេង និស្ស័យ ចុះថ្ងៃទី៣១-៥-៨៨ និង ចុះថ្ងៃទី ០៤-៦-១៩៨៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៧-១០-៨៧ របស់តំណាង នៃធនាគារជាតិ នៃកម្ពុជា ឈ្មោះកាង គួងហ៊ាង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣ - កែប្រែចំណុចទី១ នៃសាលក្រមលេខ ១០៧ "ក" ចុះថ្ងៃទី១១-៨-៨៧ របស់តុលាការក្រុងភ្នំពេញ ថា :

ក - ផ្តន្ទាទោសឈ្មោះ ហេង គឹមអ៊ី ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ២២-៥-៨៧ ពីបទប៉ុនប៉ងធ្វើអោយខូចខាតដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃតាមមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង បទមិនគោរពការកិច្ចរបស់ខ្លួន តាមមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ ។

ខ - ផ្តន្ទាទោសឈ្មោះ ហេង និស្ស័យ ភេទប្រុសអាយុ៣២ឆ្នាំ ជាតិចិនខាង ដាក់ពន្ធនាគារ កំណត់ ០១ឆ្នាំ គិតពីថ្ងៃឃុំខ្លួន "២[illegible]-៥-៨៧" ពីបទប៉ុនប៉ងធ្វើអោយខូចខាតដោយចេតនា នូវទ្រព្យសម្បត្តិអ្នកដទៃតាមមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង បទមិនគោរពការកិច្ចរបស់ខ្លួន តាមមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ ។

៤ - ចំណុចឯទៀតនៃសាលក្រមនេះត្រូវតម្កល់ទុកជាបានការដដែល ។

៥ - សាលដីកានេះជំនុំជំរះ ជាសាធារណៈចំពោះមុខជនជាប់ចោទ - ឈ្មោះ ហេង គឹមអ៊ី និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ ហេង និស្ស័យ នៅថ្ងៃទី១៨-៦-៨៨ ។ ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ហេង គឹមអ៊ី និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ ហេង និស្ស័យ នៅថ្ងៃទី ២២-៦-៨៨ វេលាម៉ោង បីរសៀល បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៨៨ របស់លោក - កាង គួងហ៊ាង តំណាងអោយធនាគារជាតិ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៤១ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ១៩៨៨ របស់ សាលាឧទ្ធរណ៍ លើចំណុចទី ៣-ក.ខ នៃសេចក្តីសំរេច ។

បានឃើញ សារណា ចុះថ្ងៃទី១១ ខែវិច្ឆិកាឆ្នាំ១៩៨៨ របស់លោកកាង គួងហ៊ាង តំណាងអោយធនាគារជាតិ នៃកម្ពុជា ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៨៨ របស់ឈ្មោះ ហេង គឹមអ៊ី និង ឈ្មោះ ហេង និស្ស័យ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានស្តាប់ទឡ្ហីករណ៍ របស់មេធាវីក្រុមទឡ្ហីករណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា៖
ពុំមានភស្តុតាងដើម្បីចោទប្រកាន់លើឈ្មោះ ទេង គឹមអ៊ី និង ឈ្មោះ ទេង និស័យ ពីបទប៉ុនប៉ង
ធ្វើអោយខូចខាតដោយចេតនាលើទ្រព្យសម្បត្តិអ្នកដទៃ និង មិនគោរពការកិច្ចរបស់ខ្លួនទេ ។
ប៉ុន្តែជនជាប់ចោទពុំបានប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ តាមច្បាប់កំណត់ឡើយ ។

១- បណ្តឹងសាទុក្ខរបស់ឈ្មោះ កាង គុងហ៊ាង តំណាងអោយធនាគារជាតិ នៃកម្ពុជា ធ្វើឡើង
ក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

២- ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី ២២-៦-៩៨ របស់សាលា -
ឧទ្ធរណ៍ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោក កាង គុងហ៊ាង តំណាង
អោយធនាគារជាតិ បានថ្លែងថា៖ បទល្មើសព្រហ្មទណ្ឌសេដ្ឋកិច្ចដែលមានឥទ្ធិពលខ្លាំងក្លា ដែលប្រព្រឹត្ត
ដោយលោកទេង គឹមអ៊ី និង ទេង និស័យ នេះគឺមានទ្រង់ទ្រាយធំ ចំណែក ឯដើមទុនរបស់លោក
ទេង គឹមអ៊ីមានតែ បីលានដុល្លាជាង ចំពោះការចេញលិខិតស្នាមទាំងអស់ និង ទម្លាយការណ៍របស់
ធនាគារពាណិជ្ជ ត្រូវមានការបញ្ជាក់ អោយបានច្បាស់ ហើយផ្ញើរមកធនាគារជាតិ ដើម្បីធ្វើ
ការត្រួតពិនិត្យ ។ ចំពោះដើមទុនរបស់លោកទេង គឹមអ៊ីមានលក្ខណៈខុស និងច្បាប់ទាំងស្រុង
ចំណែកការចេញលិខិតធានាជាប្រតិបត្តិការឥណទាន និង ការក្លែងបន្លំរបស់លោកទេង គឹមអ៊ី មាន
កំរិតខ្ពស់ មិនត្រឹមត្រូវតាមច្បាប់ទេ ឥណទានអាចទទួលសេចក្តីទុកចិត្តអោយបង់ប្រាក់ឯកទៅប្រើប្រាស់
តែការធានារបស់លោកទេង គឹមអ៊ី ជាការធានាគ្មានលក្ខខ័ណ្ឌ ធនាគារខ្មែរដែលបើកនេះ គឺ
មានដើមទុនខុសច្បាប់ ប៉ុន្តែគេមានលិខិតស្នាមត្រឹមត្រូវចំពោះមុខធនាគារជាតិ ចំពោះការ
ចេញលិខិត ជាសិទ្ធិរបស់ធនាគារខ្មែរ ប៉ុន្តែការចេញលិខិតត្រូវមានអ្វីជាកំបាំង ។ ចំណែក
អ្នកទទួលខុសត្រូវផង គឺធនាគារខ្មែរ ។ ហើយខ្លួនមានច្បាប់ដែលបញ្ជាក់ថាការធានា គឺជា
ឥណទាន ។ គឺខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលនេះ គឺការសំរេចដាក់ទោសនៅស្រាលពេក គឺ
សុំអោយតុលាការកំពូល ផ្តល់យុត្តិធម៌ ពីព្រោះលិខិតធានាទាំង ៧ច្បាប់មានតម្លៃសរុបដល់ទៅ -
១.១៧២.០០០.០០០ដុល្លា ត្រូវបានចេញអោយភាគីផ្សេងគ្នា និង សុំអោយតុលាការកំពូលសំរេច
អោយជនត្រូវចោទទាំងអស់រួមគ្នាសងជំងឺចិត្តអោយធនាគារជាតិ ចំនួន១០.០០០.០០០រៀល ជា
បន្ថែម លើប្រាក់ពិន័យ ។ អាស្រ័យហេតុនេះសូមក្រុមប្រឹក្សា មេត្តាសំរេច ។

បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ ទេង គឹមអ៊ី ៖បានថ្លែងថា ៖ ចំពោះ
ការលើកឡើងរបស់លោកចៅក្រម និង លោកព្រះរាជអាជ្ញា គឺមានយុត្តិធម៌ ដល់រូបខ្ញុំ ។
ចំពោះការចោទប្រកាន់របស់ធនាគារជាតិ មកលើរូបខ្ញុំនេះ គឺមិនត្រឹមត្រូវឡើយ ចំណែករឿង
ដើមទុន រកស៊ីរបស់ខ្លួនមានចំនួន ៤លានដុល្លា ខ្លួនពុំបានធ្វើខុស និងអនុក្រឹត្យទេ ការធ្វើលិខិតរបស់
ខ្លួនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ទាំងអស់ ។ ឥណទាននៅស្រុកខ្មែរគ្មានច្បាប់ហាមឃាត់ទេ
ឥណទានកុំប្រចាំ និង ការធានាឥណទាន គឺការយកលុយដល់ដៃផ្ទាល់ម ៗ ការធានានាំពាក់លុយមិនសង
អ្នកធានាត្រូវតែសង ចំពោះធនាគារខ្មែរមុនធ្វើអ្វីខ្លួន សួរតែសុំទៅធនាគារជាតិរាល់ការ
ចេញលិខិត ។ ធនាគារខ្មែរជាអ្នកជួយធានាស្រួចចំពោះរឿងលិខិតវិញខ្ញុំមិនដែលបានបំពេញ
ដើម្បីយកទៅធនាគារជាតិទេ រាល់ការធ្វើលិខិតទាំងអស់ គឺខ្ញុំបានកំរៃ ចំពោះកំរៃនេះ គឺបាន
មកពីអ្នកខ្ចីលុយ ។ នាចុងក្រោយខ្ញុំសុំអោយតុលាការកំពូលបដិសេធចោលទាំងស្រុង និង ទុកជាអា
សារបង់ នូវសាលក្រមរបស់តុលាការក្រុងភ្នំពេញ និង សាលដីកាសាលាឧទ្ធរណ៍ ហើយសុំអោយខ្ញុំរួច
ពីទោស និង សុំទាមទារជម្ងឺចិត្ត ពីធនាគារជាតិ ។

បានស្តាប់អំណានសារណា របស់ ជនជាប់ចោទឈ្មោះ ទេង និស័យ

បានស្តាប់សេចក្តីបន្ថែមរបស់មេធាវីការពារឈ្មោះ ហេង គឹមអ៊ី ថា : លោក ហេង គឹមអ៊ី ជាប្រធាន ដែលមានដើមទុនជាទឹកប្រាក់ចំនួន ៤លានដុល្លារអាមេរិក ហើយធនាគារខ្មែរបានទទួលអាជ្ញាប័ណ្ណអនុញ្ញាតិអោយប្រកបអាជីវកម្មពីថ្ងៃទី២៨-១០-១៩៩៦ គឺបាន១៧ថ្ងៃធនាគារជាតិ នៃកម្ពុជា បានចេញលិខិតផ្អាកអាជ្ញាប័ណ្ណបណ្តោះអាសន្ន ។ គឺបានចេញលិខិតធានាចំនួន ៧ ដែលក្នុងនោះមានលិខិតធានាបី ជាលិខិតធានាប្រភេទពុំដកហូតវិញបាន និងគ្មានលក្ខខ័ណ្ឌ ។ ប៉ុន្តែលិខិតធានាទាំងនេះ អាចនឹងមានប្រសិទ្ធិភាពបាន លុះត្រាតែធនាគារខ្មែរ បានទទួលការធានាបន្ត ពីធនាគារអន្តរជាតិ ។ លិខិតធានានេះ ក្នុងគោលបំណងជួយអោយមានធនក្នុងការអភិវឌ្ឍន៍លើផ្នែកកសិឧស្សាហកម្ម ដូចក្នុងគំរោងរបស់លោក មិត្ត ស៊ីឃួន លោកប្រាក់ វ៉ាន់សេន់ និង អ្នកស្រី-ណា វណ្ណី ។ ជាចុងក្រោយសុំអោយតុលាការមេត្តាបញ្ចប់នីតិវិធីតុលាការត្រឹមតុលាការកំពូលលើកទី១ នេះ ដើម្បីថ្វាយព្រះមហាក្សត្រ ប្រទានព្រះរាជទានអភ័យទោស និង អោយលោក - ហេង គឹមអ៊ី បានរួចផុតពីការឃុំឃាំងក្នុងពេលឆាប់ៗ ដោយអនុគ្រោះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ គ្មានអ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋានដើមនៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់តំណាងធនាគារជាតិ របស់ជនជាប់ចោទឈ្មោះ - ហេង គឹមអ៊ី ស្តាប់សារណារបស់ជនជាប់ចោទឈ្មោះ ហេង និស៊ីរុយ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៨ របស់លោក កាំង ស៊ុងហ៊ាង តំណាងអោយធនាគារជាតិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់មហាសាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ធនាគារជាតិតំណាងដោយលោកកាំង ស៊ុងហ៊ាង ក្នុងសារណាចុះថ្ងៃទី១១-១១-៩៨ ទាមទារសុំតម្លើងទណ្ឌកម្ម ទៅលើឈ្មោះ ហេង គឹមអ៊ី និងឈ្មោះ ហេង និស៊ីរុយ និង សុំទាមទារបន្ថែមនូវប្រាក់ជម្ងឺចិត្តចំនួន១០.០០០.០០០រៀល ទៀតនោះជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា:

+ ការដែលឈ្មោះ ហេង គឹមអ៊ី និង ឈ្មោះហេង និស៊ីរុយ ចេញលិខិតធានាកន្លងមកពុំមានធាតុផ្សំគ្រប់គ្រាន់កំណត់ថាជាបទល្មើសប៉ុនប៉ង ធ្វើអោយខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឡើយ ។

+ ម្យ៉ាងទៀតតាមមាត្រា៩.១២.១៣ និងមាត្រា១៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មានតែបុគ្គលដែលរងគ្រោះផ្ទាល់ពីអំពើល្មើសទេ ទើបអាចធ្វើបណ្តឹងរដ្ឋប្បវេណីបាន ។

- យល់ឃើញថា ការដែលឈ្មោះហេង គឹមអ៊ី បានអះអាងក្នុងសារណា ចុះថ្ងៃទី - ១៧-៩-៩៨ ក៏ដូចជាក្នុងពេលសវនាការថា ការដែលខ្លួនចេញលិខិតធានាកន្លងមកពុំមែនជាអំពើល្មើស នោះជាការពុំត្រឹមត្រូវឡើយ ពីព្រោះក្នុងចំណោមលិខិតធានាទាំង៧នោះ មានលិខិតធានាលេខ តេការិលពេញ ០៤ លេខតេការិលពេញ ០៥ និង លេខតេការិលពេញ ០៧ គឺជាលិខិតធានាពុំអាចដកហូតបានគ្មានលក្ខខ័ណ្ឌអាចផ្ទេរបាន អាចបែងចែកបាន មានការទទួលស្គាល់ពីធនាគារ និងត្រូវសងវិញនៅពេលដែលគេសុំអោយសងដំបូង ហើយលិខិតទាំងបីនេះក៏គ្មានដាក់ថាត្រូវតែមាន

ការធានា បន្តដោយធនាគារបរទេសថ្នាក់លើទីជរ ដូច្នេះធនាគារខ្មែរ ពុំបានបង្ការនូវហានិភ័យដែលអាចកើតមានឡើងនៅពេលម្ចាស់បំណុលមកទារលុយ ។ សកម្មភាពទាំងនេះ គឺជាការរំលោភទៅលើច្បាប់ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ ។

- យល់ឃើញថា ជនជាប់ចោទឈ្មោះ ហេង និស្ស័យ បានផ្ញើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទឈ្មោះ ហេង និស្ស័យ ប៉ុន្តែបាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី២២-៦-៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចផ្តន្ទាទោសឈ្មោះ ហេង គឹមអ៊ី និង ឈ្មោះ ហេង និស្ស័យតាមមាត្រា៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង តាមមាត្រា១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ខ្លះ ខុសខ្លះ ប៉ុន្តែដោយជនជាប់ចោទ ពុំបានប្តឹងសាទុក្ខតុលាការកំពូលគប្បីតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី២២-៦-៩៨ របស់ សាលាឧទ្ធរណ៍ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងធនាគារជាតិ និង ជនជាប់ចោទឈ្មោះ ហេង គឹមអ៊ី កំបាំងមុខជនជាប់ចោទឈ្មោះ ហេង និស្ស័យ ប៉ុន្តែបាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨ របស់ លោក កាង តុងហ៊ាង តំណាងអោយធនាគារជាតិ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៤១ ចុះថ្ងៃទី២២-៦-៩៨ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ។